ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៧៨.១៤.នក.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ គ្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ ០៣២០ រថ.អធរ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

# សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនិងសិទ្ធិផាកពិន័យលើបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ធ្វើឱ្យរាងចាលដល់បុគ្គលប្រព្រឹត្តល្មើសតាមរយៈការបង់ប្រាក់ផាកពិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការផាកពិន័យលើបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី ដូចមានចែងក្នុងមាត្រា៣៣ថ្មី មាត្រា៣៤ថ្មី មាត្រា៣៥ថ្មី មាត្រា៣៦ថ្មី មាត្រា៣៧ថ្មី និងមាត្រា៣៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ៤.-**

មន្ត្រីមានសមត្ថកិច្ច សំដៅដល់សមាជិកក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចដែលមានភារកិច្ចត្រួតពិនិត្យលើបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល និង/ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត។

មន្ត្រីអធិការកិច្ចធនធានរ៉ែ សំដៅដល់សមាជិកក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ដែលមានភារកិច្ចត្រួតពិនិត្យលើបទល្មើសប្រតិបត្តិការធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល និង/ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ស្របតាមមាត្រា២៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ៥.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងរ៉ែនិងថាមពល អាចធ្វើការផាកពិន័យលើបទល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ នៅ

ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែត្រូវចុះហត្ថលេខាលើលិខិតផាកពិន័យ និងមានសិទ្ធិប្រើប្រាស់ត្រាផ្លូវការរបស់ក្រសួងរ៉ែនិងថាមពល។

មន្ត្រីមានសមត្ថកិច្ចនៃមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត អាចធ្វើការផាកពិន័យនូវរាល់អំពើល្មើសក្នុងដែនដីរាជធានី ខេត្តសាមី។

ការផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើនេះ ត្រូវមានការឯកភាពដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជាមុនពីប្រធានក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច។

## ប្រការ៦..

ការសម្រេចអំពីទឹកប្រាក់នៃការផាកពិន័យលើបទល្មើសត្រូវផ្អែកតាមលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖

- ការប្រព្រឹត្តល្មើសដោយចេតនា
- ការប្រព្រឹត្តល្មើសលើកដំបូង
- ទំហំនៃបទល្មើស ឬទំហំនៃវត្ថុតាងដែលបុគ្គលបានប្រព្រឹត្តល្មើស និង
- ទំហំខូចខាតនិងផលប៉ះពាល់ដល់សង្គម សេដ្ឋកិច្ចនិងបរិស្ថាន។

## ប្រការ៧..

ការផាកពិន័យអាចប្រព្រឹត្តទៅបាននៅនឹងកន្លែងឬមិននៅនឹងកន្លែង។ ការផាកពិន័យនៅនឹងកន្លែង មន្ត្រីមានសមត្ថកិច្ចដែលមានសិទ្ធិផាកពិន័យ ដូចមានចែងក្នុងប្រការ៥ខាងលើត្រូវចេញលិខិតផាកពិន័យដោយផ្អែកលើកំណត់ហេតុអធិការកិច្ច និងត្រូវទទួលបានការឯកភាពដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ក្នុងករណីការធ្វើអធិការកិច្ច ពុំស្ថិតក្រោមការដឹកនាំរបស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច។

គំរូលិខិតផាកពិន័យមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ប្រការ៨..

ក្នុងករណីការផាកពិន័យត្រូវបានអនុវត្តដោយក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចក្រសួងរ៉ែនិងថាមពល ហើយមិនអាចប្រព្រឹត្តទៅបាននៅនឹងកន្លែង មន្ត្រីមានសមត្ថកិច្ចត្រូវប្រគល់ឯកសារចាំបាច់នានាពាក់ព័ន្ធនឹងករណីល្មើសជូននាយកដ្ឋានជំនាញទទួលបន្ទុករ៉ែដែលជាកម្មវត្ថុនៃអំពើល្មើស សម្រាប់ធ្វើការគណនានូវទំហំទឹកប្រាក់ផាកពិន័យ ស្របតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ រួចស្នើសុំគោលការណ៍ឯកភាពជាមុនពីប្រធានក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ដើម្បីអគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែចេញលិខិតផាកពិន័យ ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាបង់ប្រាក់។

ក្នុងករណីការផាកពិន័យត្រូវបានអនុវត្តដោយក្រុមការងារអធិការកិច្ចមកពីមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ហើយមិនអាចប្រព្រឹត្តទៅបាននៅនឹងកន្លែង មន្ត្រីមានសមត្ថកិច្ចត្រូវប្រគល់ឯកសារចាំបាច់នានាពាក់ព័ន្ធនឹងករណីល្មើសជូនការិយាល័យធនធានរ៉ែនៃមន្ទីររ៉ែនិងថាមពលរាជធានី ខេត្តនោះ ធ្វើការគណនានូវទំហំទឹកប្រាក់ផាកពិន័យ ស្របតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការ

គ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ក្នុងរយៈពេល៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការរួចស្នើសុំគោលការណ៍ឯកភាពជាមុនពីប្រធានក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ដើម្បីប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ចេញលិខិតផាកពិន័យ ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាបង់ប្រាក់។

លិខិតបញ្ជាបង់ប្រាក់ត្រូវកំណត់កាលបរិច្ឆេទឱសានវាទ ៣០(សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតផាកពិន័យ។

គំរូលិខិតបញ្ជាបង់ប្រាក់មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៩.-**

បុគ្គលប្រព្រឹត្តល្មើសដែលត្រូវបានផាកពិន័យដូចមានចែងក្នុងប្រការ៨ខាងលើត្រូវយកលិខិតផាកពិន័យមកក្រសួងរ៉ែនិងថាមពល ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដើម្បីទទួល លិខិតបញ្ជាបង់ប្រាក់និងទៅបង់ប្រាក់ផាកពិន័យនៅធនាគារ តាមការកំណត់នៅក្នុងលិខិតបញ្ជាបង់ប្រាក់។

បុគ្គលប្រព្រឹត្តល្មើសដែលត្រូវបានផាកពិន័យដូចមានចែងក្នុងប្រការ៩ខាងលើត្រូវទៅបង់ប្រាក់ផាកពិន័យនៅធនាគារ តាមការកំណត់នៅក្នុងលិខិតបញ្ជាបង់ប្រាក់។

ការយឺតយ៉ាវក្នុងការបង់ប្រាក់ផាកពិន័យនឹងត្រូវទទួលការពិន័យបន្ថែម ស្របតាមច្បាប់និងបទប្បញ្ញត្តិដែលមានជាធរមាន។

**ប្រការ១០.-**

ក្នុងករណីបុគ្គលប្រព្រឹត្តល្មើសមិនសហការតាមនីតិវិធីផាកពិន័យខាងលើ មន្ត្រីអធិការកិច្ចធនធានរ៉ែដែលបំពេញបេសកកម្ម ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរដែនដីមានសមត្ថកិច្ច មានសិទ្ធិចាត់វិធានការលើវត្ថុតាង ដកហូតឯកសារពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការធនធានរ៉ែ បញ្ឈប់សកម្មភាពផ្នែកណាមួយឬទាំងស្រុងជាបណ្ដោះអាសន្ន។ មន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីពិនិត្យនិងចាត់វិធានការបន្តតាមនីតិវិធី។

បុគ្គលប្រព្រឹត្តល្មើស ដែលត្រូវបានមន្ត្រីអធិការកិច្ចធនធានរ៉ែចាត់វិធានការលើវត្ថុតាងត្រូវទទួលបន្ទុកចំណាយក្នុងការលើកដាក់ ដឹកជញ្ជូន និងថែរក្សាវត្ថុតាង នៅក្នុងដំណើរការដោះស្រាយបទល្មើស។

**ប្រការ១១.-**

ក្រោយពេលបុគ្គលប្រព្រឹត្តល្មើសបានបង់ប្រាក់ផាកពិន័យគ្រប់ចំនួនរួច មន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវប្រគល់វត្ថុតាងនៃបទល្មើសជូនបុគ្គលប្រព្រឹត្តល្មើសវិញ លើកលែងតែវត្ថុតាងដែលជាផលិតផលមានគ្រោះថ្នាក់ ឬសារធាតុហាមឃាត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

**ប្រការ១២.-**

បុគ្គលដែលមិនសុខចិត្តនឹងការផាកពិន័យ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលមិនលើសពី២០(ម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតផាកពិន័យ។ លិខិតតវ៉ាត្រូវបញ្ជាក់កម្មវត្ថុនៃការតវ៉ានិងទឡ្ហីករណ៍ច្បាស់លាស់ ដោយមានឯកសារដោះបន្ទុកភ្ជាប់មកជាមួយ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនឹងធ្វើការសម្រេចជាចុងក្រោយលើការផាកពិន័យនេះ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៕

ថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែនិងថាមពល**

**អគ្គនាយកដ្ឋានធនធានរ៉ែ**

**លេខៈ**................................ រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០......

**អគ្គនាយកដ្ឋានធនធានរ៉ែ**

**<u>ជម្រាបមក</u>**

**លោក /លោកស្រី/ ក្រុមហ៊ុន**......................................................................

**កម្មវត្ថុ** ៖ ការពិន័យអន្តរការណ៍/ផាកពិន័យជាប្រាក់លោក/លោកស្រី/ក្រុមហ៊ុន៖.................................នូវចំនួនទឹកប្រាក់.................................................. (.........................................................)
សម្រាប់ករណីធ្វើប្រតិបត្តិការធនធានរ៉ែ ......................................................................។

**យោង** ៖- ប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- ប្រកាសលេខ ០២០ រថ.អធរ.ប្រក របស់ក្រសួងរ៉ែ និងថាមពល ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១៥
- កំណត់ហេតុអធិការកិច្ច ចុះថ្ងៃ.......ខែ.........ឆ្នាំ២០...........
- ........................................................................................................................
- ........................................................................................................................

តបតាមកម្មវត្ថុនិងយោងខាងលើ អគ្គនាយកដ្ឋានធនធានរ៉ែ តម្រូវឱ្យ.............................បង់ប្រាក់ផាកពិន័យសម្រាប់ប្រតិបត្តិការ..........................................................................................................។

លោក/លោកស្រី/ ក្រុមហ៊ុនត្រូវបានផាកពិន័យក្នុងកម្រិតអប្បបរមាដែលត្រូវបានកំណត់ដូចខាងក្រោម៖

**ឧបសម្ព័ន្ធទី១(ក)**

**នៃប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិង ការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

| ចំណុចត្រូវពិន័យ | ល្មើសនឹងចំណុច ........ ........ ........ | ល្មើសនឹងចំណុច ........ ........ ........ | កាលបរិច្ឆេទអាជ្ញាបណ្ណផុតសុពលភាពឬ ........ ........ ........ | កាលបរិច្ឆេទដាក់ពាក្យពន្យារបន្តអាជ្ញាបណ្ណ ឬ ........ ........ ........ | ចំនួនថ្ងៃត្រូវពិន័យ ឬ ........ ........ | ចំនួនទឹកប្រាក់ត្រូវពិន័យ ........ ........ ........ | សរុប |
|---|---|---|---|---|---|---|---|
| ធ្វើប្រតិបត្តិការរ៉ែ ដោយ........ ........ ........ ........ ........ | ........ ........ ........ រៀល/ថ្ងៃ | ........ ........ ........ រៀល/ថ្ងៃ | | | | | |
| សរុបទឹកប្រាក់ត្រូវបង់ | | | | | | | |

លោក/លោកស្រី/ក្រុមហ៊ុន ត្រូវបង់ទឹកប្រាក់សរុបចំនួន........................(.................................................) ចំពោះករណីលោក លោកស្រី ក្រុមហ៊ុន បានធ្វើប្រតិបត្តិការរ៉ែ ដោយ.................................................................................................................................................................................................. ។

អគ្គនាយកដ្ឋានធនធានរ៉ែ កំណត់ពេលជូនក្រុមហ៊ុនរបស់លោក/លោកស្រី/ក្រុមហ៊ុនមកបង់ប្រាក់ពិន័យ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ក្នុងករណីមានការយឺតយ៉ាវ នឹងត្រូវរងការពិន័យ ២% ក្នុង១ខែ និងអាចឈានទៅដល់ការបញ្ចប់ការធ្វើអាជីវកម្មនៅតំបន់............................................ ......................................................................................................................................................... ។

អាស្រ័យហេតុនេះ សូមលោក/លោកស្រី/ក្រុមហ៊ុនជ្រាប និងអនុវត្តឲ្យមានប្រសិទ្ធភាព។

**អគ្គនាយក**

ចម្លងជូន:
-នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ
-មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត........................
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១(ខ)

នៃប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិង ការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរ៉ែនិងថាមពល**

**មន្ទីររ៉ែនិងថាមពល**...............................

**លេខ:**........................ ធ្វើនៅ.................. ថ្ងៃទី ខែ ឆ្នាំ២០......

**មន្ទីររ៉ែនិងថាមពល** ...............................

**ជម្រាបមក**

**លោក /លោកស្រី/ ក្រុមហ៊ុន**.........................................................................

**កម្មវត្ថុ ៖** ការពិន័យអន្តរការណ៍/ផាកពិន័យជាប្រាក់លោក/លោកស្រី/ក្រុមហ៊ុន៖...............................
នូវចំនួនទឹកប្រាក់................................................ (.................................................)
សម្រាប់ករណីធ្វើប្រតិបត្តិការធនធានរ៉ែ ..........................................................................។

**យោង ៖**
- ប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសរួមលេខ១៤៥១ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល។
- ប្រកាសលេខ០២០ រថ.អធរ.ប្រក របស់ក្រសួងរ៉ែ និងថាមពល ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១៥
- កំណត់ហេតុអធិការកិច្ច ចុះថ្ងៃ.......ខែ........ឆ្នាំ២០...........
- ...................................................................................................................
- ...................................................................................................................

តបតាមកម្មវត្ថុនិងយោងខាងលើ មន្ទីររ៉ែនិងថាមពល................................ តម្រូវឱ្យលោក/លោកស្រី/ក្រុមហ៊ុនបង់ប្រាក់ផាកពិន័យសម្រាប់ប្រតិបត្តិការធនធានរ៉ែ ...................................................
..................................................................................................................................។

ក្រុមហ៊ុនត្រូវបានផាកពិន័យក្នុងកម្រិតអប្បបរមាដែលត្រូវបានកំណត់ដូចខាងក្រោម៖

**ឧបសម្ព័ន្ធទី១(ខ)**

**នៃប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ គ្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

| ចំណុចត្រូវពិន័យ | ល្មើស<br>នឹងចំណុច<br>..........<br>..........<br>.......... | ល្មើស<br>នឹងចំណុច<br>..........<br>..........<br>.......... | កាលបរិច្ឆេទ<br>អាជ្ញាបណ្ណ<br>ផុតសុពលភាពឬ<br>..........<br>..........<br>.......... | កាលបរិច្ឆេទ<br>ដាក់ពាក្យពន្យារ<br>បន្តអាជ្ញាបណ្ណ ឬ<br>..........<br>..........<br>.......... | ចំនួនថ្ងៃ<br>ត្រូវពិន័យ<br>ឬ<br>..........<br>.......... | ចំនួនទឹកប្រាក់ត្រូវ<br>ពិន័យ<br>..........<br>..........<br>.......... | សរុប |
|---|---|---|---|---|---|---|---|
| ធ្វើប្រតិបត្តិការរ៉ែ<br>ដោយ..........<br>..........<br>..........<br>..........<br>.......... | ..........<br>..........<br>..........<br>រៀល/ថ្ងៃ | ..........<br>..........<br>..........<br>រៀល/ថ្ងៃ | | | | | |
| សរុបទឹកប្រាក់ត្រូវបង់ | | | | | | | |

លោក/លោកស្រី/ក្រុមហ៊ុន ត្រូវបង់ទឹកប្រាក់សរុបចំនួន......................(..............................................) ចំពោះករណីលោក/លោកស្រី/ក្រុមហ៊ុន បានធ្វើប្រតិបត្តិការរ៉ែ ដោយ...................................................................................................................................................................................................................។

មន្ទីររ៉ែនិងថាមពល កំណត់ពេលជូនក្រុមហ៊ុនរបស់លោក/លោកស្រី/ក្រុមហ៊ុនមកបង់ប្រាក់ពិន័យ ក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ក្នុងករណីមានការយឺតយ៉ាវ នឹងត្រូវរងការពិន័យ ២% ក្នុង១ខែ និងអាចឈានទៅដល់ការបញ្ចប់ការធ្វើអាជីវកម្មនៅតំបន់.................................................................................................................................................................................។

អាស្រ័យហេតុនេះ សូមលោក/លោកស្រី/ក្រុមហ៊ុនជ្រាប និងអនុវត្តឲ្យមានប្រសិទ្ធភាព។

**មន្ទីររ៉ែនិងថាមពល.................................**

**ប្រធាន**

<u>ចម្លងជូន:</u>
-នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ
-មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត.......................
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី២(ក)
នៃប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែនិងថាមពល**

.....................................................

លេខ:.................................................

........-.........................-........................…………

# លិខិតបញ្ជាបង់ប្រាក់
# ចំណូលលើតម្លៃធនធានរ៉ែ

**យោង ៖**
- ប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ
- សេចក្តីណែនាំលេខ០២៦៣រថ.អធរ.សណន ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង់ប្រាក់អត្ថប្រយោជន៍បន្ថែមមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាននិងមូលនិធិសម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាពចំពោះ ធនធានរ៉ែសំណង់
- ប្រកាសអន្តរក្រសួងលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់ប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល។

បានបញ្ជាក់ថាឈ្មោះ.................................... ភេទ........... តំណាងឱ្យក្រុមហ៊ុន/អាជីវករ.......................................................................................... កាន់អាជ្ញាបណ្ណ.................................................... លេខ...............................ដែលមានទីតាំងនៅ.................................................................................................ត្រូវបង់ប្រាក់ចំណូលលើតម្លៃធនធានរ៉ែ................................. ឆ្នាំ...............ចំនួន USD..................(.........................................................................) ប្រាក់ចំណូលមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋានសម្រាប់.........................ឆ្នាំ...........ចំនួន USD......................(..............................................................)និង ប្រាក់ពិន័យអន្តរការណ៍ចំនួន USD......................(..............................................................) ដែលមានទឹកប្រាក់សរុបចំនួន USD............................(.............................................................................) នៅធនាគារ/សាខាធនាគារកាណាឌីយ៉ា................................ មិនឲ្យហួសពីថ្ងៃទី.......... ខែ......... ឆ្នាំ.................ដូចខាងក្រោម៖

| ល.រ | យថាប្រភេទចំណូល/ខ្ទង់ចំណូល | សេចក្តីបង្គាប់ | ទឹកប្រាក់ | ឈ្មោះគណនី | លេខគណនី |
|---|---|---|---|---|---|
| ក | ចំណូលសួយសារ | Deposit | | (P1)គណនីចំណូលលើតម្លៃធនធានរ៉ែខេត្ត................. | (P1) |
| | កំណត់ចំណាំសម្រាប់មន្ត្រីមន្ទីរ | | | | |
| ក.1 | ចំណូលថ្នាក់ជាតិ | Transfer | | គណនីរតនាគារខេត្ត................ | |
| ក.2 | ចំណូលថ្នាក់ក្រោមជាតិ | Transfer | | គណនីរតនាគារខេត្ត................. | |
| ក.3 | ចំណូលកាត់ទុក | Transfer | | (P2)គណនីប្រាក់រង្វាន់កាត់ទុក១០% | |

| ល.រ | យថាប្រភេទចំណូល/ខ្ទង់ចំណូល | សេចក្តីបង្គាប់ | ទឹកប្រាក់ | ឈ្មោះគណនី | លេខគណនី |
|---|---|---|---|---|---|
| ខ | ចំណូលអត្ថប្រយោជន៍បន្ថែម | Deposit | | (P1)គណនីចំណូលលើតម្លៃធនធានរ៉ែខេត្ត............. | (P1) |
| | កំណត់ចំណាំសម្រាប់មន្ត្រីមន្ទីរ | | | | |
| ខ.1 | ចំណូលថ្នាក់ជាតិ | Transfer | | គណនីរតនាគារខេត្ត...................... | |
| ខ.2 | ចំណូលថ្នាក់ក្រោមជាតិ | Transfer | | គណនីរតនាគារខេត្ត...................... | |
| ខ.3 | ចំណូលកាត់ទុក | Transfer | | (P2)គណនីប្រាក់រង្វាន់កាត់ទុក១០% | |

ក្រសួងរ៉ែនិងថាមពល

**ឧបសម្ព័ន្ធទី២(ក)**

**នៃប្រកាសស្ដីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្ដូងរ៉ែបើកនិងការដ្ឋាន**
**វាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

| ល.រ | យថាប្រភេទចំណូល/ខ្ទង់ចំណូល | សេចក្ដីបង្គាប់ | ទឹកប្រាក់ | ឈ្មោះគណនី | លេខគណនី | |
|---|---|---|---|---|---|---|
| គ | ចំណូលមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន | Deposit | | (P8) គណនីមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន | (P8) | |
| ឃ | ចំណូលពីការពិន័យអន្តរការណ៍ | Deposit | | (P5) គណនីចំណូលពីការពិន័យអន្តរការណ៍ | (P5) | |

ថ្ងៃ.......................... ខែ............ឆ្នាំ...............ព.ស.២៥៦...
............................... ថ្ងៃទី............ ខែ.......... ឆ្នាំ២០.......
**រដ្ឋលេខាធិការចំណូល.......**

បានឃើញនិងឯកភាពក្នុងការទទួលបង់ប្រាក់
ចំនួនទឹកប្រាក់សរុប៖...........................
អាជីវករ/តំណាងក្រុមហ៊ុន

(ឈ្មោះ)

ឧបសម្ព័ន្ធទី២(ខ)

នៃប្រកាសស្ដីពីនីតិវិធីនៃការដាក់ពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្ដូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែនិងថាមពល**

........................................................

លេខ:.................................................

| ......- ............................-............................ |
|---|

# លិខិតបញ្ជាបង់ប្រាក់

## ចំណូលកម្រៃសេវាសាធារណៈធនធានរ៉ែ

**យោង ៖** - ប្រកាសស្ដីពីនីតិវិធីនៃការដាក់ពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណអណ្ដូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

- ប្រកាសអន្តរក្រសួងលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់ប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- ប្រកាសអន្តរក្រសួងលេខ ១៤៥២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បានបញ្ជាក់ថាឈ្មោះ........................... ភេទ...........តំណាងឱ្យក្រុមហ៊ុន/អាជីវករ.................................................................................................................................កាន់អាជ្ញាបណ្ណ................................................................ លេខ.........................
នៅតំបន់.........................ភូមិ.........................ឃុំ..........................ស្រុក...........................ខេត្ត.....................................ត្រូវបង់ប្រាក់................................... ចំនួន............................(...............................................................................................) នៅធនាគារ/សាខាធនាគារកាណាឌីយ៉ារាជធានីភ្នំពេញ មិនឱ្យហួសពីថ្ងៃទី............ ខែ........... ឆ្នាំ.............. ដូចខាងក្រោម៖

| ល.រ | យថាប្រភេទចំណូល/ខ្ទង់ចំណូល | សេចក្ដីបង្គាប់ | ចំនួនទឹកប្រាក់ | ឈ្មោះគណនី | លេខគណនី |
|---|---|---|---|---|---|
| ១ | ចំណូលកម្រៃសេវាសាធារណៈ ............................................... | Deposit | | (M2)គណនីចំណូលពីកម្រៃសេវាសាធារណៈធនធានរ៉ែ | |
| ២ | ចំណូលពីការពិន័យអន្តរការណ៍ | Deposit | | (M2)គណនីចំណូលពីកម្រៃសេវាសាធារណៈធនធានរ៉ែ | |

ថ្ងៃ........................... ខែ............ឆ្នាំ...............ព.ស.២៥៦...

............................... ថ្ងៃទី............ ខែ........... ឆ្នាំ២០.......

**រដ្ឋលេខាធិការចំណូល**........

បានឃើញនិងឯកភាពក្នុងការទទួលបង់ប្រាក់

ចំនួនទឹកប្រាក់សរុប៖.............................

អាជីវករ/តំណាងក្រុមហ៊ុន

(ឈ្មោះ)

ឧបសម្ព័ន្ធទី២(គ)

នៃប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋាន

វាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែនិងថាមពល**

.....................................................

លេខៈ ..........................................

| ......- ..............................-.............................. |
|---|

## លិខិតបញ្ជាបង់ប្រាក់
## ចំណូលពីការបង់ឈ្នួលដី

**យោង** ៖ - ប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

- ប្រកាសអន្តរក្រសួងលេខ ៦៦៤ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់ថ្លៃឈ្នួលដីតំបន់អាជ្ញាបណ្ណធនធានរ៉ែ
- បទបញ្ជាលេខ០៤បប ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

បានបញ្ជាក់ថាឈ្មោះ..........................ភេទ.........តំណាងឱ្យក្រុមហ៊ុន.......................................................................................
កាន់អាជ្ញាបណ្ណ.......................................................................លេខ.......................... នៅតំបន់..........................ភូមិ......................
ឃុំ..........................ស្រុក.................................ខេត្ត.......................... ត្រូវបង់ប្រាក់កម្រៃឈ្នួលដីចំនួន USD..............................
(.............................................................................................) នៅធនាគារ/សាខាធនាគារកាណាឌីយ៉ា..................... មិនឱ្យហួសពីថ្ងៃទី
........ ខែ............. ឆ្នាំ.............. ដូចខាងក្រោមៈ

<u>**កំណត់ចំណាំ</u>

| ល.រ | យថាប្រភេទចំណូល/ ខ្ទង់ចំណូល | សេចក្តីបង្គាប់ | ទឹកប្រាក់ | ឈ្មោះគណនី | លេខគណនី |
|---|---|---|---|---|---|
| ក | ចំណូលពីការបង់ឈ្នួលដី (........................) | Deposit | | (M6) គណនីចំណូលឈ្នួលដីតំបន់អាជ្ញាបណ្ណធនធានរ៉ែ | |
| ខ | ចំណូលពីការពិន័យអន្តរការណ៍ ........... ខែ | Deposit | | (M4) គណនីចំណូលពីការពិន័យអន្តរការណ៍ | |

បានឃើញនិងឯកភាពក្នុងការទទួលបង់ប្រាក់

ចំនួនទឹកប្រាក់សរុបៈ.............................

អាជីវករ/តំណាងក្រុមហ៊ុន

(ឈ្មោះ)

ថ្ងៃ............................. ខែ............ឆ្នាំ................ព.ស.២៥៦...

................................ ថ្ងៃទី............ ខែ........... ឆ្នាំ២០........

**រដ្ឋលេខាធិការទទួលបន្ទុកចំណូល**.........